អាជ្ញាធរអគ្គិសនីកម្ពុជា

EAC

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ ៩១៤ សាណ.១៧ អអក

ភ្នំពេញ, ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៧

## សេចក្ដីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ស្ដីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាបណ្ណរបស់ លោកស្រី គិន វិភាវី សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅឃុំជំនីក ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ផ្នែកខ្លះនៃស្រុកឆ្លូង ស្រុកចិត្របុរី ឃុំស្វាយជ្រះ ស្រុកស្នួល និងសង្កាត់កោះកណ្ដាល ក្រុងក្រចេះ ខេត្តក្រចេះ

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយសសូមជម្រាបជូនសាធារណជននៅក្នុងឃុំជំនីក ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ស្រុកឆ្លូង ស្រុកចិត្របុរី ឃុំស្វាយជ្រះ ស្រុកស្នួល និងសង្កាត់កោះកណ្ដាល ក្រុងក្រចេះ ខេត្តក្រចេះ ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាបានចេញអាជ្ញាបណ្ណលេខ ១៩១ អ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ ឲ្យលោកស្រី គិន វិភាវី សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅឃុំជំនីក ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ផ្នែកខ្លះនៃស្រុកឆ្លូង ស្រុកចិត្របុរី ឃុំស្វាយជ្រះ ស្រុកស្នួល និងសង្កាត់កោះកណ្ដាល ក្រុងក្រចេះ ខេត្តក្រចេះ ក្នុងអាណត្តិមុនគឺ ១០ឆ្នាំ ។ ដោយពិនិត្យឃើញថា ក្នុងអាណត្តិនេះលោកស្រី គិន វិភាវី បានសាងសង់ និងកែលម្អមធ្យោបាយធ្វើសេវាកម្មអគ្គិសនីរបស់ខ្លួនស្របតាមស្តង់ដាបច្ចេកទេសអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្ដីសម្រេចកែសម្រួលអាជ្ញាបណ្ណឲ្យលោកស្រី គិន វិភាវី ដោយផ្ដល់អាណត្តិអាជ្ញាបណ្ណចំនួន ១២(ដប់ពីរ)ឆ្នាំ បន្តទៀត ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការកែសម្រួលអាជ្ញាបណ្ណ អាជ្ញាធរមូលដ្ឋាន ស្ថាប័ននានាដែលពាក់ព័ន្ធ និងសាធារណជនមានសិទ្ធិពិនិត្យផ្ដល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាលើខ្លឹមសារនៃសេចក្ដីព្រាងសេចក្ដីសម្រេចកែសម្រួលអាជ្ញាបណ្ណដែលគ្រោងនឹងចេញនេះ ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្ដីព្រាងសេចក្ដីសម្រេចកែសម្រួលអាជ្ញាបណ្ណនៅ......................
..........................................................................................................សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះ សូមសាធារណជននៅក្នុងឃុំជំនីក ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ស្រុកឆ្លូង ស្រុកចិត្របុរី ឃុំស្វាយជ្រះ ស្រុកស្នួល និងសង្កាត់កោះកណ្ដាល ក្រុងក្រចេះ ខេត្តក្រចេះ ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្ដល់យោបល់លើខ្លឹមសារនៃការចេញសេចក្ដីសម្រេចកែសម្រួលអាជ្ញាបណ្ណឲ្យលោកស្រី គិន វិភាវី អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្ដល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះ រហូតដល់ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ ។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា " អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានបង្ហាញនូវហេតុផលយ៉ាងច្បាស់លាស់ប៉ុណ្ណោះ" ។

អាជ្ញាធរអគ្គិសនីកម្ពុជា

ប្រធាន

បណ្ឌិត.ឆី នរិន្ទ